# សេចក្តីសង្ខេបគោលនយោបាយ

ខែតុលា ២០១៥

## យុទ្ធសាស្ត្រជាសក្តានុពល ដើម្បីគាំទ្រដល់កសិករដែលមានដីធ្លីតូចតាចនៅកម្ពុជា

ដោយៈ សួន សេង អាម៉ូរីភីធើរ ឈាង សុខមៅ និងចាយ គាថា

## សេចក្តីសង្ខេបនៃការសិក្សាៈ

ការសិក្សាស្តីអំពី "ការឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច" ត្រូវបានធ្វើឡើងក្នុងកំឡុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១៥ ដោយក្រុមស្រាវជ្រាវ នៃមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កសិកម្ម និងប្រព័ន្ធចិញ្ចឹមជីវិត(សិនដរ) ក្រោមការគាំទ្រមូលនិធិថវិកាពី វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ ការសិក្សាធ្វើឡើងដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដូចខាងក្រោមៈ

- តើគោលនយោបាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានផ្តល់អាទិភាពលើវិស័យកសិកម្មក្នុងកម្រិតណាចំពោះគ្រួសារកសិករ ដែលមានដីធ្លីតូចតាច និងក្រុមហ៊ុនដីសម្បទាន?
- តើរាជរដ្ឋាភិបាលកម្ពុជា មានតួនាទីអ្វីខ្លះក្នុងការគាំទ្រដល់គ្រួសារកសិករ ដែលមានដីធ្លីតូចតាច និងក្រុមហ៊ុនដីសម្បទានក្នុងប្រទេសកម្ពុជា?
- តើអ្វីជាភាពតានតឹង ដែលអាចកើតមានរវាងការគាំទ្រការពង្រីកគម្រោងកសិកម្មខ្នាតធំ និងការគាំទ្រគ្រួសារកសិករដែលមានដីធ្លីតូចតាច?
- តើមានមេរៀនអ្វីខ្លះ ដែលទទួលបានពីការសិក្សាស្រាវជ្រាវ ដើម្បីប្រើប្រាស់ក្នុងការគាំទ្រដល់គ្រួសារកសិករដែលមានដីធ្លីតូចតាច?
- តើមេរៀនដែលទទួលបានពីករណីសិក្សាអាចយកទៅអនុវត្តឲ្យបានទូលំទូលាយយ៉ាងដូម្តេច?

ដើម្បីឆ្លើយតបទៅ នឹងសំណួរស្រាវជ្រាវខាងលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ឯកសារ និងគោលនយោបាយពាក់ព័ន្ធមួយចំនួនដែលទាក់ទិននឹងការអភិវឌ្ឍកសិកម្មនៅកម្ពុជា ត្រូវបានសិក្សា។ អ្នកផ្តល់ព័ត៌មានសំខាន់ៗ នៅថ្នាក់ជាតិដែលធ្វើកិច្ចការក្នុងការអភិវឌ្ឍកសិកម្មនៅកម្ពុជា ត្រូវបានសម្ភាស។ ករណីសិក្សាចំនួន៤នៃអង្គការមិនមែនរដ្ឋាភិបាលចំនួន ២ (សេដាក និងអេសអិនវី) ត្រូវបានធ្វើឡើង ដើម្បីឈ្វេងយល់ពីយុទ្ធសាស្ត្រអ្វីខ្លះដែលបានប្រើប្រាស់ និង របៀបនៃការតភ្ជាប់កសិករទៅកាន់ទីផ្សារ។

## សារនយោបាយអភិវឌ្ឍន៍សំខាន់ៗ

- កសិកម្ម គឺជាវិស័យអាទិភាព សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងសន្តិសុខស្បៀង។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ផ្តោតសំខាន់លើការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការធ្វើទំនើបកម្ម ពិពិធកម្ម និងពាណិជ្ជូបនីយកម្ម ដោយពុំមានផ្តល់អាទិភាពច្បាស់លាស់លើកសិកម្មខ្នាតតូច ឬ ខ្នាតធំឡើយ។ ទោះយ៉ាងណា គោលនយោបាយនេះ បានបង្កើតនូវភាពតានតឹងចំពោះកសិកម្មខ្នាតតូច ដោយសារថា កសិកម្មខ្នាតធំបានកើនឡើងយ៉ាងឆាប់រហ័ស ហើយអាចគ្របដណ្តប់វិស័យកសិកម្មធំទូលាយនៅពេលអនាគតខាងមុខ។
- ឧបករណ៍គតិយុត្តមួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់កសិករដែលមានដីធ្លីតូចតាចក្នុងការបង្កើនផលិតភាពកសិកម្ម និងទីផ្សារ សម្រាប់ផលិតផលរបស់ពួកគាត់។ ទោះយ៉ាងណាកសិករនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនក្នុងការរៀបចំចងក្រងជាក្រុម ឬ សហគមន៍ឲ្យបានល្អប្រសើរ

ដើម្បីបំពេញតាមស្តង់ដារគុណភាព ផលិតផល ការដោះស្រាយជាមួយនឹង ធាតុចូលកសិកម្មដែលមានតម្លៃខ្ពស់ គុណភាពគ្រាប់ពូជមិនល្អ និង សមត្ថភាពហិរញ្ញវត្ថុ ដែលនៅមានកម្រិតនៅឡើយ។

- ការតភ្ជាប់កសិករដែលមានដីធ្លីតូចតាច ទៅកាន់ទីផ្សារ គឺជាចលករដ៏សំខាន់ឆ្ពោះទៅដល់កំណើនសេដ្ឋកិច្ច ប៉ុន្តែវាមាននូវប្រព័ន្ធសាំញ៉ាំមួយដែលរួមមានទាំងកត្តាប្រឈម និងការរំពឹងទុក។ ដើម្បីឈានចេញពីសន្តិសុខស្បៀង ក្នុងគ្រួសារទៅកាន់ទីផ្សារនៅទីក្រុង ឬ ទីផ្សារនាំចេញ កសិករដែលមានដីធ្លីតូចតាចចាំបាច់ត្រូវរៀនសូត្រពីការធ្វើអាជីវកម្ម និងលក្ខខណ្ឌតម្រូវការនៃទីផ្សារ។ ដើម្បីធ្វើកិច្ចការនេះបាន វាមិនត្រឹមតែជាការគិតគូរតែទៅលើការបង្កើនទំហំលក់ប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏តម្រូវឲ្យមានការយកចិត្តទុកដាក់ធានាលើផ្នែកគុណភាព និងការកំណត់ជាក់លាក់ នៃផលិតផលផងដែរ។ កសិករផលិត ត្រូវតែគោរពច្បាប់អាជីវកម្ម ដូចជា៖ បរិមាណ ពេលវេលាផ្គត់ផ្គង់ គុណភាព និងលក្ខខណ្ឌតម្រូវជាក់លាក់ផ្សេងទៀតផងដែរ។
- ទស្សនៈអភិវឌ្ឍន៍ចំនួន ២ ត្រូវបានអនុវត្ត។ ការអភិវឌ្ឍបែបអាស្រ័យលើខ្លួនឯង ជួយឲ្យកសិករអាចគ្រប់គ្រងចង្វាក់អាជីវកម្មរបស់ពួកគាត់បាន ប៉ុន្តែដំណើរការនេះ ទាមទារនូវការប្តេជ្ញាចិត្តរយៈពេលយូរដើម្បីបង្កើតឡើង ខណៈយុទ្ធសាស្រ្តអាជីវ-កម្មបែបបរិយាប័ន្ន បានផ្តល់នូវអត្ថប្រយោជន៍ដល់កសិករក្នុងរយៈពេលឆាប់រហ័ស ប៉ុន្តែអ្នកផលិតមានឱកាសតិចតួចក្នុងការគ្រប់គ្រងចង្វាក់អាជីវកម្មដោយខ្លួនឯង។
- ការអនុវត្តយុទ្ធសាស្រ្តទីផ្សារ គឺផ្អែកលើធម្មជាតិ នៃប្រភេទផលិតផលដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សា និងភាពរួចរាល់របស់ភាគីពាក់ព័ន្ធក្នុងប្រភេទផលិតផលទាំងនោះ។ យុទ្ធសាស្រ្តប្រមូលផ្តុំពីមូលដ្ឋាន មានកម្លាំងរុញដែលជួយដល់កសិករអ្នកផលិត ឲ្យរៀបចំចងក្រងគ្នាជាក្រុម/សហគមន៍ និងពង្រឹងសិទ្ធិអំណាច ខណៈដែលយុទ្ធសាស្រ្តចង្វាក់សាកលមានកម្លាំងទាញ ដើម្បីលើកទឹកចិត្ត និងបង្កើតភាពក្លាហានដល់កសិករឲ្យឈានចូលទៅក្នុងប្រព័ន្ធទីផ្សារ។ យុទ្ធសាស្រ្តទាំង ២ នេះ ឬ ការផ្តុំបញ្ចូលគ្នានូវយុទ្ធសាស្រ្តទាំងពីរ មានលក្ខណៈសមស្រប ដើម្បីគាំទ្រដល់កសិករដែលមានដីធ្លីតូចតាច។ ទោះយ៉ាងនេះក្តីក្នុងដំណាក់កាលដំបូងនៃការតភ្ជាប់កសិករទៅកាន់ទីផ្សារ និងដើម្បីជួយពួកគាត់ក្នុងការប្រឈមនឹងកត្តាទីផ្សារបានយុទ្ធ-សាស្រ្តប្រមូលផ្តុំពីមូលដ្ឋាន គឺជាជម្រើសល្អបំផុតមួយ។

## របកគំហើញសំខាន់ៗ៖ លទ្ធផល និងការវិភាគ

- គោលនយោបាយទាំងអស់ផ្តល់អាទិភាពទៅលើវិស័យកសិកម្មដូចដែលមានចែងក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ វិស័យនេះ ជាតំណាងនៃសរសរស្តម្ភមួយក្នុងចំណោមសរសរស្តម្ភទាំង៤ នៃយុទ្ធសាស្រ្តចតុកោណ (ដំណាក់កាលទី៣) របស់រាជរដ្ឋាភិបាលកម្ពុជា ហើយត្រូវបានទទួលស្គាល់ថាបានដើរតួនាទីជាសំខាន់ ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច ដោយមិនត្រឹមតែជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទប៉ុណ្ណោះទេ ថែមទាំងក្នុងន័យសមភាព និងសន្តិសុខស្បៀងផងដែរ។
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ មិនបានផ្តល់អាទិភាពជាក់លាក់ណាមួយចំពោះកសិកម្មខ្នាតធំ ឬ ខ្នាតតូចឡើយប៉ុន្តែបានផ្តល់នូវគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីលើកកម្ពស់វិស័យកសិកម្ម។ គំនិតផ្តួចផ្តើមទាំងនោះ ត្រូវបានជំរុញតាមរយៈការយកចិត្តទុកដាក់លើការធ្វើ ទំនើបកម្មកសិកម្ម ក្នុងទិសដៅផ្លាស់ប្តូរពីការធ្វើកសិកម្មបែបប្រពៃណី មកកសិកម្មតាមបែបបច្ចេកទេសទំនើប

ពិពធកម្ម តាមរយៈការទទួលយកនូវប្រភេទដំណាំទាំងឡាយណាដែលមានតម្លៃទីផ្សារខ្ពស់ ជាពិសេសសំដៅឆ្ពោះទៅទីផ្សារនាំចេញ និងការធ្វើពាណិជ្ជូប-នីយកម្ម ដែលផ្តោតសំខាន់លើការលើកកម្ពស់ជំនួញ និងការនាំចេញផលិតផលកសិកម្ម។

- **ការគាំទ្រកសិករ មានដីធ្លីតូចតាច៖** ឧបករណ៍គតិយុត្តពាក់ព័ន្ធមួយចំនួន ត្រូវបានបង្កើតឡើង ដោយរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសាម៉ី។ ឧបករណ៍គតិយុត្តទាំងនោះរួមមាន៖ គោលនយោ-បាយពូជស្រូវ និងពូជដំណាំបន្ទាប់បន្សំ គោលនយោបាយស្តង់ដាកសិកម្មសរីរាង្គកម្ពុជា គោលនយោបាយនាំអង្ករចេញ និងច្បាប់ស្តីពីសហគមន៍កសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំគ្រប់គ្រង គាំទ្រ និងធានាថា សេចក្តីថ្លែងគោលនយោបាយ និងការប្តេជ្ញាចិត្តលើការអភិវឌ្ឍកសិកម្មទាំងឡាយ អាចសម្រេចបាន ទន្ទឹមគ្នានោះធានាបាននូវសន្តិសុខ និងសុវត្ថិភាពស្បៀងនៅកម្ពុជា។

- **ការគាំទ្រក្រុមហ៊ុនសម្បទានខ្នាតធំ៖** ដើម្បីគាំទ្រដល់ក្រុមហ៊ុនសម្បទានខ្នាតធំ អនុក្រឹត្យស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចត្រូវបានបង្កើតឡើង។ បន្ថែមលើសនេះ បទបញ្ជា ០១ និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់អ្នកកាន់កាប់ដីពីមុនៗ តាមរយៈគោលនយោបាយស្បែកខ្លា ក៏ត្រូវបានអនុវត្តដើម្បីដោះស្រាយជម្លោះរវាងសហគមន៍ក្នុងតំបន់ និងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចខ្នាតធំក្នុងរង្វង់ដែនដីសម្បទានសេដ្ឋកិច្ច។ ដូច្នេះ វាអាចសម្រួលដល់ការអនុវត្តការផ្តល់ដីសម្បទានខ្នាតធំបានដោយរលូន។

- **ការបំពេញសន្តិសុខស្បៀង ជាលក្ខណៈគ្រួសារ៖** ផលិតកម្មស្បៀងជាលក្ខណៈគ្រួសារគឺជាចំណុចចាប់ផ្តើមដែលត្រូវតែបំពេញ មុនពេលបន្តដំណើរជាបណ្តើរៗ ទៅកម្រិតបន្ទាប់ទៀត។ ភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាសំខាន់ផ្តល់ការកសាងសមត្ថភាពបច្ចេកទេស ស្តីពីផលិតកម្មកសិកម្ម និងសម្របសម្រួលកសិករឲ្យទទួលបានធាតុចូលកសិកម្មដូចជា គ្រាប់ពូជដែលមានគុណភាព ជី និងសម្ភារៈផ្សេងទៀតសម្រាប់ផលិតកម្ម។

- **ការលើកកម្ពស់ផលិតកម្ម សម្រាប់ទីផ្សារក្នុងស្រុក និងសន្តិសុខស្បៀង៖** នៅកម្រិតទី២ការចងក្រងក្រុមកសិករ គឺត្រូវការជាចំបាច់។ វិស័យឯកជនដើរតួនាទីជាអ្នកចែកចាយ ឬអ្នកលក់រាយ។ លើសពីនេះ កសិករអាចលក់ផលិតផលរបស់ពួកគេក្នុងមូលដ្ឋានទៅអ្នកជិតខាង ឬ ទីផ្សារក្នុងតំបន់។ ភ្នាក់ងាររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់ផលិតផលក្នុងស្រុក តាមរយៈការដាក់តាំងពិពណ៌កសិកម្ម។ អ្នកផលិតជាលក្ខណៈបុគ្គល និងក្រុមអ្នកផលិតជាបន្តបន្ទាប់ ត្រូវបានស្គាល់ដោយអ្នកប្រើប្រាស់នៅទីប្រជុំជន ហើយនៅពេលនោះអ្នកប្រើប្រាស់អាចទិញផលិតផលទាំងនោះបានដោយផ្ទាល់ពីកសិករ។

- **ការលើកកម្ពស់ផលិតកម្ម ឆ្ពោះទៅទីផ្សារនាំចេញ៖** ភ្នាក់ងាររដ្ឋាភិបាល បានផ្តល់នូវការគាំទ្រផ្លូវច្បាប់ ខណៈដែលក្រុមហ៊ុននាំចេញបានធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក ដើម្បីទិញនូវផលិតផលតាមចំនួនជាតម្រូវការសម្រាប់នាំចេញ។ អង្គការមិនមែនរដ្ឋាភិបាល ជាញឹកញាប់ធ្វើការជាមួយក្រុមអ្នកផលិត និងបង្កើតគ្នាជាក្រុម និង/ឬ ចុះឈ្មោះជាសហគមន៍កសិកម្ម។ ក្រុមហ៊ុននាំចេញកម្រធ្វើការដោយផ្ទាល់ជាមួយសហគមន៍កសិកម្មណាស់ ប៉ុន្តែពួកគេបានធ្វើការ តាមរយៈឈ្មួញកណ្តាល ឬក្រុមហ៊ុនក្នុងស្រុក។

- **ការតភ្ជាប់កសិករទៅកាន់ទីផ្សារ៖** មានន័យថា ធ្វើការកំណត់ជាទៀងទាត់នូវគំរូផ្គត់ផ្គង់ ដើម្បីធានាថា កសិករអាចទទួលបាននូវអត្ថប្រយោជន៍ពីផលិតកម្មកសិកម្មជាបន្តបន្ទាប់។ ការធ្វើផែនការ

ផលិត និងជំនាញក្នុងការរៀបចំក្រុមអ្នកផលិត គឺជារឿងចាំបាច់ ដើម្បីជួយដល់កសិករអាចមានលទ្ធភាពចូលទៅកាន់ទីផ្សារ។ ការតភ្ជាប់កសិករទៅកាន់ទីផ្សារ គួរត្រូវបានពង្រីកចេញពីទីផ្សារក្នុងតំបន់ទៅទីផ្សារនៅទីក្រុង និងបន្ទាប់មកទៅកាន់ទីផ្សារនាំចេញ។ ហេតុនេះ ការគាំទ្រណាមួយពីរដ្ឋាភិបាល វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាលចំពោះកសិករមានដីធ្លីតូចតាចគឺជាការចាំបាច់បំផុត។

- **យុទ្ធសាស្ត្រអភិវឌ្ឍន៍បែបអាស្រ័យលើខ្លួនឯង៖** ទស្សនៈនេះ ត្រូវបានអនុវត្តដោយអង្គការសេដាក ដែលបានប្រើប្រាស់ទៅលើគឺ ស្រូវ និងបន្លែ។ សហគមន៍គោលដៅបានរៀបចំចងក្រងគ្នា ក្នុងន័យធនធានមនុស្ស រូបសាស្ត្រ និងហិរញ្ញវត្ថុ តាមរយៈការផ្តល់នូវគំនិត និងសមត្ថភាពបច្ចេកទេស ដែលត្រូវបានផ្តល់ដោយអង្គការសេដាក។

- **យុទ្ធសាស្ត្រអាជីវកម្មបែបបរិយាប័ន្ន៖** ទស្សនៈនេះ ត្រូវបានអនុវត្តដោយអង្គការអេសអិនវី ទៅលើទីផ្សារដំឡូងមី។ រចនាសម្ព័ន្ធទីផ្សារដែលមានស្រាប់នេះ ត្រូវបានសម្របសម្រួលដោយភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការលើកកម្ពស់ និងរក្សានូវរចនាសម្ព័ន្ធអាជីវកម្ម ដោយការបែងចែកផលប្រយោជន៍ទាំងអស់គ្នា។

- **យុទ្ធសាស្ត្រប្រមូលផ្តុំពីមូលដ្ឋាន៖** យុទ្ធសាស្ត្រទីផ្សារនេះត្រូវបានអនុវត្តដោយអង្គការសេដាក ទៅលើប្រភេទបន្លែផ្សេងៗ ដើម្បីផ្សារភ្ជាប់ផលិតផលនេះទៅកាន់ទីផ្សារ។ យុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងតាមរយៈ ការចងក្រង និងការប្រមូលផ្តុំនូវកសិករតូចតាចជាអ្នកផលិត សម្រាប់ផលិតផលជាក់លាក់ណាមួយ។ យុទ្ធសាស្ត្រប្រមូលផ្តុំពីមូលដ្ឋានជាទូទៅ ត្រូវបានកំណត់ត្រឹមក្របខណ្ឌសមត្ថភាពផលិតកម្មក្នុងតំបន់ ជាជាងការជំរុញដោយទំហំតម្រូវការពីខាងក្រៅ។

- **យុទ្ធសាស្ត្រចង្វាក់សាកល៖** យុទ្ធសាស្ត្រទីផ្សារប្រភេទនេះ ត្រូវបានអនុវត្តដោយអង្គការអេសអិនវី ទៅលើប្រភេទកសិផលដំឡូងមីក្នុងការតភ្ជាប់ប្រភេទកសិផលនេះ ទៅកាន់ទីផ្សារក្នុងស្រុកផង និងទីផ្សារនាំចេញផង។ យុទ្ធសាស្ត្រចង្វាក់សាកល ជាទូទៅត្រូវបានជំរុញដោយទំហំតម្រូវការពីប្រទេសខាងក្រៅ ដែលជាញឹកញាប់ត្រូវបានធ្វើឡើងតាមរយៈការធ្វើកសិកម្មតាមកិច្ចសន្យា។

- **ការផ្គុំបញ្ចូលគ្នានូវយុទ្ធសាស្ត្រទីផ្សារទាំងពីរ៖** សេដាកបានធ្វើការតាមរយៈ ការផ្គុំបញ្ចូលគ្នានូវយុទ្ធ-សាស្ត្រទីផ្សារទាំងពីរ នៅក្នុងអន្តរាគមន៍របស់ខ្លួនទៅលើទីផ្សារស្រូវសរីរាង្គ។ ជាជំហានដំបូង ក្រុមកសិករផលិតស្រូវសរីរាង្គ បានចងក្រងគ្នាជាក្រុមនៅកម្រិតភូមិ ហើយបន្ទាប់មកផ្គុំបញ្ចូលគ្នានៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ។ អង្ករសរីរាង្គ មានគោលដៅទីផ្សារជាច្រើនទាំងនៅទីផ្សារក្នុងទីក្រុង និងទីផ្សារនាំចេញ។ សហគ្រាសសេដាក បានទិញស្រូវសរីរាង្គពីកសិករ ហើយកិនលក់ឲ្យអ្នកបរិភោគក្នុងទីក្រុង។ លើសពីនេះ សេដាកក៏បានដើរតួជាឈ្មួញកណ្តាល និងសហប្រតិបត្តិការជាមួយក្រុមហ៊ុននាំចេញ ដើម្បីនាំអង្ករចេញទៅទីផ្សារបរទេស ឧទាហរណ៍ សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិកជាដើម។ ក្នុងករណីនេះ ក្រុមហ៊ុននាំអង្ករចេញ បានចុះកិច្ចសន្យាជាមួយអង្គការសេដាក នូវបរិមាណអង្ករសរីរាង្គ ក្នុងចំនួនណាមួយ។ សេដាក ធ្វើការសម្របសម្រួលជាមួយកសិករ ដើម្បីផលិតស្រូវសរីរាង្គ សម្រាប់បំពេញតាមតម្រូវការនាំចេញ។ តម្រូវការអង្ករសរីរាង្គ ត្រូវបានកំណត់ដោយទីផ្សារនាំចេញ ឬ អ្នកបញ្ជាទិញ ហើយដែលពួកគេធ្វើការជាមួយក្រុមហ៊ុនក្នុងស្រុក ដែលនៅពេលនេះ (សហគ្រាសសេដាក) គឺត្រូវបានស្គាល់ថាជាយុទ្ធសាស្ត្រចង្វាក់សាកល។

# អនុសាសន៍សំខាន់ៗ

- រដ្ឋាភិបាលគួរបង្កើនល្បឿន ក្នុងការរៀបចំបង្កើតឯកសារក្របខណ្ឌគតិយុត្ត និងសេវាគាំទ្របច្ចេកទេស ដើម្បីបង្កើតសហគមន៍កសិកម្មដូចជាៈ សម្ភារៈបណ្តុះបណ្តាល/រៀនសូត្រ (ទី១-ឧបករណ៍ស្តីអំពីការអនុវត្ត និងការគ្រប់គ្រងសហគមន៍កសិកម្ម និង ទី២-ឧបករណ៍បណ្តុះបណ្តាលគ្រូបង្គោល)។ រហូតដល់ពេលបច្ចុប្បន្ន រដ្ឋាភិបាលបានបង្កើតនាយកដ្ឋានសហគមន៍កសិកម្ម ដែលស្ថិតក្រោមអគ្គនាយកដ្ឋានកសិកម្ម។ ទោះយ៉ាងណា សៀវភៅមេរៀនសម្រាប់ការអនុវត្តសហគមន៍កសិកម្ម នៅមិនទាន់បានរៀបចំរួចរាល់នៅឡើយទេ។
- រដ្ឋាភិបាលកម្ពុជា គួរផ្តោតការគាំទ្ររបស់ខ្លួនចំពោះកសិករ ខណៈដែលភស្តុតាងបានបង្ហាញថា ចំណេះដឹងផ្នែកបច្ចេកទេសកសិកម្មសមស្រប និងការសម្របសម្រួលទីផ្សារ រួមនឹងលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុប្រសើរជាងមុន អាចនាំឆ្ពោះទៅការអភិវឌ្ឍដែលអាស្រ័យលើខ្លួនឯងបាន និងប្រកបដោយនិរន្តរភាព ជាពិសេស ដោយវាមានទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រស្តីអំពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភថ្នាក់ជាតិផងដែរ។
- យុទ្ធសាស្ត្រតាមបែបប្រមូលផ្តុំពីមូលដ្ឋានគួរត្រូវបានទទួលយក ដើម្បីរៀបចំចងក្រងក្រុមកសិករអ្នកផលិតក្នុងដំណាក់កាលដំបូង ក្នុងការផ្សារភ្ជាប់កសិករទៅទីផ្សារ។ ជាពិសេស ក្នុងបរិបទសហគមន៍អាស៊ាន សហគមន៍កសិកម្មគួរត្រូវបានបង្កើតឡើង ដោយផ្អែកទៅលើប្រភេទផលិតផលកសិកម្មសំខាន់ៗ និងធ្វើការពង្រឹងឲ្យរឹងមាំ។
- រហូតមកដល់បច្ចុប្បន្ន សហព័ន្ធសហគមន៍កសិកម្មត្រូវបានបង្កើតឡើង និងកំពុងមានដំណើរការ។ ស្ថិតនៅក្រោមក្របខណ្ឌសហព័ន្ធ សហគមន៍កសិកម្មបានគៀរគរធនធានហិរញ្ញវត្ថុ ពីសមាជិកសហគមន៍កសិកម្មរបស់គាត់ ដើម្បីវិនិយោគទៅលើរោងម៉ាស៊ីនកិនស្រូវថ្នាក់ស្រុក។ រដ្ឋាភិបាលគួររៀបចំឲ្យមានមូលនិធិ ដើម្បីគាំទ្រសហគមន៍កសិកម្ម ឬសហព័ន្ធ។ មូលនិធិនេះ ក៏គួរអាចទទួលបានដោយផ្ទាល់ដោយសហគមន៍កសិកម្ម ដើម្បីពង្រឹងនិងពង្រីកខ្នាតអាជីវកម្មរបស់ពួកគាត់។

## ការអះអាងៈ

រាល់ទស្សនៈទាំងឡាយដែលមាននៅក្នុងសេចក្តីសង្ខេបគោលនយោបាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនតំណាងឲ្យទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការសិនដរឡើយ៕

# ឯកសារគួរអានបន្ថែម:


ADHOC, 2013, A turning point? Land, housing and natural resources rights in Cambodia in 2012, Cambodian Human Rights and Development Association.

ADHOC, 2014, Land Situation in Cambodia 2013, Cambodian Human Rights and Development Association.

Agrifood Consulting International (ACI), 2014, Diagnostic Study Cambodia Agriculture in Transition. Draft Final Report. Agrifood Consulting International, Kensington, Maryland, United States of America.

Castella, J.-C., 2007, Transitions Agraires et Dynamiques Environnementales en Asie du Sud-Est : D'une Gestion de Projet à une Gouvernance des Territoires, Mémoire pour l'habilitation à diriger les recherches, Université d'Avignon et des Pays du Vaucluse.

FAO, 2013. Climate-Smart Agriculture Sourcebook. Rome, FAO Gereffi, G., 1999, A Commodity Chain Framework for Analyzing Global Industries, Duke University.

Gereffi, G., 2000, Beyond the producer-driven/buyer-driven dichotomy: An Expanded Typology of Global Value Chains, with Special Reference to the Internet, Duke University.

Gironde, C. , Golay, C., Messerli, P., 2014, Large-scale land acquisitions in Southeast Asia: Rural transformations between global agendas and peoples' right to food, working paper.

Gironde, C. , Senties Protilla, G., (expected 2015), From Lagging behind to Losing Ground: Slippery Rubber Boom for Cambodian and Laotian farmers, International Development Policy Review, Special Edition on Large Scale Land Acquisitions.

Im Chhun Lim, 2012, Senior Minister and Minister of Land Management, Urban Planning and Construction and Chairman of Council of Land Policy, Speech at the GDCC, 26 September 2012, Phnom Penh.

Kumar, D., Shivay, Y., S., 2008; Modern Concepts of Agriculture. Integrated Crop Management.

Licadho, 2014, Human Rights 2013: The Year in Review, Licadho, Cambodian League for the Promotion and Defense of Human Rights, February 2014.

Löhr, D., 2011, The Cambodian Land Market: Development, Aberrations, and Perspectives, ASIEN.
Messerli, P., Schönweger, O., Peeters, A., Nanhthavong, V. V., Heinimann, A., (expected 2015), Marginal land marginal people? Analysing Patterns and Processes of Large-Scale Land Acquisitions in Southeast Asia., International Development Policy Review, Special Edition on Large Scale Land Acquisitions.

Mirza, H., Zhan, J., Speller, W., (expected 2015), The impact of larger scale agricultural investments on communities in Africa and South East Asia: Lessons from the field, UNCTAD, International Development Policy Review, Special Edition on Large Scale Land Acquisitions.

Raikes P., Jensen, M., Ponte, S., 2000, Global Commodity Chain Analysis and the French Filière Approach: Comparison and Critique, Economy and Society, Volume 29, Number 3, 1 August 2000.

Royal Government of Cambodia (RGC), 2001, Land Law, 6 February 2002, Phnom Penh.

Royal Government of Cambodia (RGC), 2003, Sub-Decree on Social Land Concessions, No. 19 ANK/BK, 19 March 2003, Phnom Penh.

Royal Government of Cambodia (RGC), 2005, Sub-Decree on Economic Land Concessions, Sub-Decree No.146, 27 December 2005, Phnom Penh.

Royal Government of Cambodia (RGC), 2011, Sub-Decree on Contract-based Agriculture Production (Contract Farming), 11 February 2011, Phnom Penh.

Royal Government of Cambodia (RGC), 2012, Directive 01 on Measures to Strengthen and Foster the Effectiveness of the Management of Economic Land Concessions, Order 01BB, 7 May 2012, Phnom Penh.

Royal Government of Cambodia (RGC), Ministry of Agriculture, Forestry and Fisheries (MAFF), 2015, Agricultural Sector Strategic Development Plan (ASSDP) 2014-2018, January 2015.

Royal Government of Cambodia (RGC), Ministry of Agriculture, Forestry and Fisheries (MAFF), 2013, Law on Agriculture Cooperatives.

Royal Government of Cambodia (RGC), Ministry of Agriculture, Forestry and Fisheries (MAFF), 2008, Law on Seed Management and Plant Breeders' Rights, 13 May 2008.

Royal Government of Cambodia (RGC), Ministry of Planning (MoP), 2014, National Strategic Development Plan (NSDP) 2014-2018.

Schönweger O., Messerli, P., Peeters, A., 2014, Beyond Anecdotal Evidence of Large Scale Land Acquisitions, Policy brief, presented at CFS, FAO, Rome, September 2013.

Sperfeldt, C., Tek, F., Chia-Ling Tai B., 2012, An Examination of Policies Promoting Large-Scale Investments in Farmland in Cambodia, Cambodian Human Rights Action Committee (CHRAC), November 2012.

Subedi, Surya P., 2012, Report of the Special Rapporteur on the situation of human rights in Cambodia, Addendum: A Human Rights Analysis of Economic and Other Land Concessions in Cambodia (UN Docs A/HCR/21/63/Add 1.

Subedi, Surya P., 2014, Report of the Special Rapporteur on the situation of human rights in Cambodia, UN Docs A/HCR/27/70.
Tirado, R., 2009. Defining ecological farming, Greenpeace Research Laboratories Technical Note 04/2009
United Nations Special Representative of the Secretary General (SRSG) for Human Rights in Cambodia, 2007, Land Concessions for Economic Purposes in Cambodia. A Human Rights Perspective, Phnom Penh, June 2007: Office of the High Commissioner for Human Rights (OHCHR).

United Nations Special Representative of the Secretary General (SRSG) for Human Rights in Cambodia, 2004, Land Concessions for Economic Purposes in Cambodia. A Human Rights Perspective, Phnom Penh, November 2004: Office of the High Commissioner for Human Rights (OHCHR).

Vorley, B., Cotula, L., Man-Kwun Chan, 2012, Tipping the balance: Policies to shape agricultural investments and markets in favour of small-scale farmers, OXFAM international & IIED, Research eport, December 2012.

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការពារប្រសើរឡើង
Working Together for Positive Change

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋាន: ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទលេខ: (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ: (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល: ngoforum@ngoforum.org.kh
គេហទំព័រ: www.ngoforum.org.kh